# ព្រះរាជក្រម

នស/រកម/០៣១៥/០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ទទួល
ចូល លេខ ៥៦៧
ថ្ងៃទី ២៧/៣ ឆ្នាំ២០១៥ ម៉ោង ១៦:២០
បញ្ជូនទៅ

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៦ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៤/០០២/២០១៥ កបធ.ច ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការបោះឆ្នោតជ្រើសតាំង
# តំណាងរាស្ត្រ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលជាសមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវអនុវត្តតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

**មាត្រា ៣.-**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើឡើងរៀងរាល់ ០៥ (ប្រាំ) ឆ្នាំម្តង ។

កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើនៅថ្ងៃអាទិត្យតែ ០១ (មួយ) ថ្ងៃ លើកលែងតែក្នុងស្ថានភាពណាមួយដូចខាងក្រោម ៖

-ក្នុងករណីប្រធានសក្តិដែលចាំបាច់ត្រូវលើកថ្ងៃបោះឆ្នោត ។

-ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ។ ក្នុងករណីនេះការបោះឆ្នោតជ្រើសតាំងរដ្ឋសភាថ្មី ត្រូវប្រព្រឹត្តទៅក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃយ៉ាងយូរ ចាប់ពីថ្ងៃរំលាយរដ្ឋសភា ។

-ក្នុងករណីដែលរដ្ឋសភាត្រូវបានប្រកាសឲ្យបន្តនីតិកាលរបស់ខ្លួន ស្របតាមកថាខណ្ឌទី ៥ នៃមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានចែងក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី ២
## ប្រព័ន្ធបោះឆ្នោត និងការកំណត់អាសនៈ

### មាត្រា ៥.-

តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រតាមរាជធានី ខេត្ត ដោយយករាជធានី ខេត្តជាមណ្ឌលបោះឆ្នោត ។

### មាត្រា ៦.-

អាសនៈនៅក្នុងរដ្ឋសភាមានចំនួន ១២៥ (មួយរយម្ភៃប្រាំ) ដែលបែងចែកតាមមណ្ឌលរាជធានី ខេត្ត ដូចខាងក្រោម ៖

| | |
|---|---|
| -មណ្ឌលខេត្តបន្ទាយមានជ័យ | ចំនួន ០៦ (ប្រាំមួយ) អាសនៈ |
| -មណ្ឌលខេត្តបាត់ដំបង | ចំនួន ០៨ (ប្រាំបី) អាសនៈ |
| -មណ្ឌលខេត្តកំពង់ចាម | ចំនួន ១០ (ដប់) អាសនៈ |
| -មណ្ឌលខេត្តត្បូងឃ្មុំ | ចំនួន ០៨ (ប្រាំបី) អាសនៈ |
| -មណ្ឌលខេត្តកំពង់ឆ្នាំង | ចំនួន ០៤ (បួន) អាសនៈ |
| -មណ្ឌលខេត្តកំពង់ស្ពឺ | ចំនួន ០៦ (ប្រាំមួយ) អាសនៈ |
| -មណ្ឌលខេត្តកំពង់ធំ | ចំនួន ០៦ (ប្រាំមួយ) អាសនៈ |
| -មណ្ឌលខេត្តកំពត | ចំនួន ០៦ (ប្រាំមួយ) អាសនៈ |
| -មណ្ឌលខេត្តកណ្ដាល | ចំនួន ១១ (ដប់មួយ) អាសនៈ |
| -មណ្ឌលខេត្តកោះកុង | ចំនួន ០១ (មួយ) អាសនៈ |
| -មណ្ឌលខេត្តក្រចេះ | ចំនួន ០៣ (បី) អាសនៈ |
| -មណ្ឌលខេត្តមណ្ឌលគិរី | ចំនួន ០១ (មួយ) អាសនៈ |
| -មណ្ឌលរាជធានីភ្នំពេញ | ចំនួន ១២ (ដប់ពីរ) អាសនៈ |
| -មណ្ឌលខេត្តព្រះវិហារ | ចំនួន ០១ (មួយ) អាសនៈ |
| -មណ្ឌលខេត្តព្រៃវែង | ចំនួន ១១ (ដប់មួយ) អាសនៈ |
| -មណ្ឌលខេត្តពោធិ៍សាត់ | ចំនួន ០៤ (បួន) អាសនៈ |
| -មណ្ឌលខេត្តរតនគិរី | ចំនួន ០១ (មួយ) អាសនៈ |

-មណ្ឌលខេត្តសៀមរាប ចំនួន ០៦ (ប្រាំមួយ) អាសនៈ
-មណ្ឌលខេត្តព្រះសីហនុ ចំនួន ០៣ (បី) អាសនៈ
-មណ្ឌលខេត្តស្ទឹងត្រែង ចំនួន ០១ (មួយ) អាសនៈ
-មណ្ឌលខេត្តស្វាយរៀង ចំនួន ០៥ (ប្រាំ) អាសនៈ
-មណ្ឌលខេត្តតាកែវ ចំនួន ០៨ (ប្រាំបី) អាសនៈ
-មណ្ឌលខេត្តកែប ចំនួន ០១ (មួយ) អាសនៈ
-មណ្ឌលខេត្តប៉ៃលិន ចំនួន ០១ (មួយ) អាសនៈ
-មណ្ឌលខេត្តឧត្តរមានជ័យ ចំនួន ០១ (មួយ) អាសនៈ ។

## ជំពូកទី ៣
## ភ្នាក់ងារគណបក្សនយោបាយ
## និងអ្នកសង្កេតការណ៍បោះឆ្នោត

### មាត្រា ៧.-

គណបក្សនយោបាយនីមួយៗដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួន ០២ (ពីរ) រូប ពេញសិទ្ធិ ០១ (មួយ) រូប និងបម្រុង០១ (មួយ) រូប ក្នុងចំណោមអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហៅថាភ្នាក់ងារគណបក្សនយោបាយ ដើម្បីចូលរួមសង្កេតការណ៍មើលការបោះ-ឆ្នោត តាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ។

ភ្នាក់ងារពេញសិទ្ធិត្រូវបានអនុញ្ញាតឲ្យចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

ភ្នាក់ងារបម្រុងត្រូវបានអនុញ្ញាតឲ្យជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីដែលភ្នាក់ងារពេញសិទ្ធិអវត្តមាន។

គណបក្សនយោបាយនីមួយៗ មានសិទ្ធិផ្លាស់ប្តូរភ្នាក់ងារគណបក្សនយោបាយរបស់ខ្លួន ។

### មាត្រា ៨.-

គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងរបស់ខ្លួនមកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជនតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣៧ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL